ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# លិខិតអបអរសាទរ

**សូមគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!**

យើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ នៃក្រសួងមុខងារសាធារណៈ សូមសម្តែងនូវអំណរសាទរយ៉ាងក្លៀវក្លា ប្រកបដោយសេចក្តីសោមនស្សរីករាយឥតឧបមា និងមានមោទនភាពបំផុតចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសដែលតុលាការយុត្តិធម៌ទីក្រុងប៉ារីស ប្រទេសបារាំង តាមរយៈសាលក្រមនាថ្ងៃទី១០ ខែតុលា ឆ្នាំ២០២២ បានផ្តល់យុត្តិធម៌ និងបញ្ជាក់ពីភាពស្អាតស្អំជូនចំពោះ **សម្តេចតេជោ** និងបានរកឃើញការពិតថា សម រង្ស៊ី បានប្រព្រឹត្តបទបរិហារកេរ្តិ៍មកលើ **សម្តេចតេជោ** យ៉ាងអយុត្តិធម៌បំផុត។

សាលក្រមរបស់តុលាការបារាំងនេះ បានបញ្ជាក់ឱ្យប្រជាជនខ្មែរ ក៏ដូចជាប្រជាជននៃពិភពលោកបានស្គាល់យ៉ាងច្បាស់ពីចរិតពិតប្រាកដរបស់ សម រង្ស៊ី ដែលហ៊ានធ្វើអំពើអសីលធម៌គ្រប់សព្វបែបយ៉ាងដើម្បីតែហេតុផលកេងចំណេញនយោបាយ ដោយបានចោទប្រកាន់យ៉ាងអយុត្តិធម៌មកលើ **សម្តេចតេជោ**។ សាលក្រមនេះ ក៏បានបង្ហាញពីភាពជោគជ័យរបស់ **សម្តេចតេជោ** ដែលទទួលបានការសម្រេចក្តីមួយសមតាមសេចក្តីប្រាថ្នារបស់ **សម្តេចតេជោ** ដែលចង់បាននូវការបញ្ជាក់ពីភាពស្អាតស្អំ និងភាពយុត្តិធម៌ ព្រមទាំងតុលាការបានទាត់ចោលការថ្លែងមួលបង្កាច់របស់បុគ្គល សម រង្ស៊ី។ ផ្ទុយទៅវិញ បុគ្គលជនជាប់ចោទ សម រង្ស៊ី ត្រូវបរាជ័យយ៉ាងធ្ងន់ធ្ងរ និងអាម៉ាស់ជាទីបំផុត ដោយតុលាការបានបញ្ជាក់យ៉ាងច្បាស់ក្នុងសាលក្រមថា ពាក្យពេចន៍របស់ខ្លួន គឺជាការចោទប្រកាន់ដោយគ្មានភស្តុតាង និងជាការបរិហារកេរ្តិ៍ ហើយត្រូវបង់ខាតចំពោះរាល់ការចំណាយទាំងអស់ក្នុងដំណើរការបណ្តឹងរបស់ខ្លួន។

ឆ្លៀតក្នុងឱកាសដ៏ប្រសើរថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នាសូមលើកហត្ថប្រណម្យឧទ្ទិសបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក តេជៈបារមីគ្រប់ទិសទី ព្រមទាំងទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមជួយប្រោះព្រំថែរក្សា ការពារ **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំង **បុត្រា បុត្រី ចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ ជន្មាយុយឺនយូរ ព្រមទាំងទទួលបានសព្វសាធុការពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ និងសម្បូរប្រកបតែនឹងព្រះពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និងភក្តីភាពដ៏ស្មោះស្ម័គ្របំផុតពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃ អង្គារ ១រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០២២

**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**

រដ្ឋមន្ត្រី

ព្រុំ សុខា

ផ្លូវវត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh